# ជំពូក៤

# ប្រវត្តិគំរោងលក្ខខ័ណ្ឌជលសាស្ត្រក្នុងខេត្តសៀមរាប

# ជំពូក៤: ស្ថានភាពជលសាស្ត្រ ក្នុងក្រុងសៀមរាប

## ៤.១. ការបែងចែកអាងទន្លេ ក្នុងតំបន់ផ្គត់ផ្គង់

ដើម្បីបែងចែកអោយបានច្បាស់ នូវអាងទន្លេ ទិន្នន័យ DEM (Digital Elevation Model) ទំហំ៩០ម នៃ SRTM (Shuttle Radar Topography Mission, USNASA) ត្រូវបានយកមកប្រើជាទិន្នន័យគោល ហើយឧបករណ៍ GIS ជលសាស្ត្រ ត្រូវបានប្រើប្រាស់ក្នុងការបែងចែកអាងទន្លេ ។




**រូបភាព ៤.១:** តំបន់សេវាកម្មផ្គត់ផ្គង់ទឹក និងអាងទន្លេដែលទាក់ទង

ដូចមានបង្ហាញក្នុងផែនទីខាងលើ តំបន់ផ្គត់ផ្គង់ទឹក គឺរួមមានអាងស្ទឹងសៀមរាប ដែលភាគខាងលិច មាន ផ្នែកខ្លះនៃអាងស្ទឹងទួលកំបុត និងនៅភាគខាងកើត មានផ្នែកខ្លះនៃអាងស្ទឹងរំលួស ។




**រូបភាព ៤.២:** តំបន់បំពេញមកវិញនៃតំបន់សេវាកម្ម ផ្គត់ផ្គង់ទឹក

តំបន់សេវាកម្មផ្គត់ផ្គង់ទឹក មានបង្ហាញក្នុងផែនទីខាងលើ ។ តំបន់បំពេញមកវិញនៃតំបន់ផ្គត់ផ្គង់ទឹកសរុប គឺ ១២៧៧ កម២ ដែលក្នុងនោះ ៥៥២ គម២ ជាតំបន់សេវាកម្មផ្គត់ផ្គង់ទឹក។

## ៤.២. ស្ថានភាពអាកាសធាតុ

ធនធានទឹក នៅក្នុងតំបន់ផ្គត់ផ្គង់ទឹក អាចចែកចេញជា ការបំពេញមកវិញដោយទឹកភ្លៀង ការហូរចេញ ដោយទន្លេ ការប្រើប្រាស់ដោយការហួត ការជ្រាបចូលក្នុងទឹកក្រោមដី និងការហូរចេញដោយទឹកក្រោមដី ។

ដោយសារតែមិនមានការហូរចូលមកពីអាងដីទៃទៀតទៅក្នុងតំបន់សិក្សា នៅពេលដែលវិភាគលើតុល្យភាពនៃទឹកក្នុងអាងទន្លេមួយនោះ ទឹកភ្លៀង គឺជាសមាសភាគតែមួយគត់ដែលត្រូវយកមកគិត ។

នៅក្នុងតំបន់ទំនាបដូចជាទីក្រុងសៀមរាបនេះ បរិមាណទឹកដែលបំពេញមកវិញ វវាំងស្ទឹង និងទឹកក្រោមដីជាទូទៅ មានតិច ។ បរិមាណទឹកក្រោមដី ដែលហូរចេញទៅបឹងទន្លេសាបក៏មានតិចដែរ ។ ដូចនេះ ទឹកភ្លៀង និងរំហួត អាចចាត់ទុកជាសមាសភាគពីរដែលសំខាន់ សំរាប់វិភាគលើតុល្យភាពទឹក ក្នុងតំបន់សិក្សា ។

ដូចជាប្រទេសនៅអាស៊ីអាគ្នេយ៍ឯទៀតផងដែរ ទឹកភ្លៀងក្នុងសៀមរាប គឺមានលក្ខណៈផ្លាស់ប្តូរទៅតាមរដូវ ។ ក្នុងឆ្នាំនិមួយៗ អាចចែកចេញជាពីររដូវ គឺរដូវវស្សា និងរដូវប្រាំង ដូចមានបង្ហាញក្នុងគំនូសបំព្រួញខាងក្រោម ។




**រូបភាព ៤.៣:** របាយទឹកភ្លៀង និងរំហួតប្រចាំខែក្នុងតំបន់សិក្សា

ក្រាហ្វិកនេះ ត្រូវបានបង្កើតឡើង ដោយសង្ខេបនូវលទ្ធផលនៃការសង្កេត នៅតាមស្ថានីយ៍ឧតុនិយមក្នុងក្រុងសៀមរាប ចាប់តាំងពីឆ្នាំ១៩៨៨ ដល់ឆ្នាំ ២០០៨ ។

### ៤.៣. ទិន្នន័យឧតុនិយមដែលមាន

ដើម្បីវិភាគលើទឹកភ្លៀង លទ្ធផលនៃការសង្កេតនៅស្ថានីយ៍ឧតុនិយមចំនួន៥ ត្រូវបានប្រមូលមកពីការិយាល័យជលសាស្ត្រ និងឧតុនិយមនៃខេត្តសៀមរាប (ក្រសួងធនធានទឹក និងឧតុនិយម នៃប្រទេសកម្ពុជា) ។

### ៤.៤. ទិន្នន័យត្រួតពិនិត្យទឹកក្រោមដីដែលមាន

#### ៤.៤.១. អណ្តូងត្រួតពិនិត្យបច្ចុប្បន្ន

អណ្តូងត្រួតពិនិត្យចំនួន៨ ត្រូវបានខួងក្នុងតំបន់សិក្សា ក្នុងការអង្កេតលើកមុន (ការសិក្សាស្តីពីប្រពន្ធ័ផ្គត់ផ្គង់ទឹកស្អាតសំរាប់សៀមរាប ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០០) ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាដែកើតមានឡើងដូចជា ការខូចនៃឧបករណ៍អង្កេត ការខ្សោយថ្មអាគុយ និងបញ្ហាផ្សេងៗ ទៀតនោះ យើងពិនិត្យឃើញថាមានកំហុសជាច្រើនកើតមានក្នុងទិន្នន័យដែលទទួលបានពីស្ទើរគ្រប់អណ្តូង ។ ដូចនេះ ការសង្កេតដោយដៃ ត្រូវបានធ្វើឡើងដោយ SRWSA ដែលត្រូវប្រើសំរាប់ត្រួតពិនិត្យ លើលទ្ធផលនៃការ សង្កេតដោយស្វ័យប្រវត្តិ ។

### ៤.៤.២. ការត្រួតពិនិត្យមើលលើលទ្ធផលនៃការពិនិត្យទឹកក្រោមដី

#### ទីតាំងត្រួតពិនិត្យ WT-3

រូបភាពខាងក្រោម បង្ហាញពីទន្នន័យត្រួតពិនិត្យដែលទទួលបានពីអណ្តូងត្រួតពិនិត្យ WT-3 ។ លើកលែងតែក្នុងរយៈពេលខ្លះដែលមិនមានទិន្នន័យ និងកំហុសនៃការសង្កេតដែលឃើញមានជាក់ស្តែងនោះ ការប្រែប្រួលនៃកំពស់ទឹកក្រោមដី ត្រូវបានបង្ហាញដោយរូបភាពខាងក្រោម ។




**រូបភាព ៤.៤:** លទ្ធផលនៃការសង្កេតលើការប្រែប្រួលកំពស់ទឹកក្រោមដី

ក្រាហ្វិកខាងលើបង្ហាញពីទិន្នន័យដែលទទួលបានពីទីតាំងត្រួតពិនិត្យ ។ ដោយសារឃើញមានកំហុសក្នុងទិន្នន័យនោះ វាចាការចាំបាច់ក្នុងការពិនត្យទិន្នន័យមុនពេលប្រើវា ។ លទ្ធផលនៃការពិនិត្យមានបង្ហាញក្នុងតារាង ៤.៥ ។




**រូបភាព ៤.៥:** ការត្រួតពិនិត្យលើទិន្នន័យពិនិត្យកំពស់ទឹកក្រោមដី

ផ្អែកតាមលទ្ធផលដែលបង្ហាញក្នុងរូបភាពខាងលើ យើងអាចសន្និដ្ឋានថា ឧបករណ៍ពិនិត្យដោយស្វ័យប្រវត្តិ នៅទីតាំង WT-3 បានកត់ត្រាដោយត្រឹមត្រូវ នូវការប្រែប្រួលកំពស់ទឹកក្រោមដី ក្នុងរយៈពេលនៃការត្រួតពិនិត្យ ទាំងមូល ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៨ ។

**ទីតាំងត្រួតពិនិត្យ WT-4**

រូបភាពខាងក្រោម បង្ហាញពីទន្នន័យត្រួតពិនិត្យដែលទទួលបានពីអណ្តូងត្រួតពិនិត្យ WT-4 ប្រៀបធៀប ទៅនឹងលទ្ធផលនៃការសង្កេតដែលទទួលបានពីអណ្តូងត្រួតពិនិត្យ WT-3 លទ្ធផលនៃការសង្កេតដែលទទួលបាន ពីអណ្តូងត្រួតពិនិត្យ WT-4 បានបង្ហាញពីភាពមិនប្រក្រតី នៃការប្រែប្រួលកំពស់ទឹកក្រោមដី ។




**រូបភាព ៤.៦:** លទ្ធផលនៃការសង្កេតលើការប្រែប្រួលកំពស់ទឹកក្រោមដី (WT-3)

ក្រាហ្វិកខាងលើបង្ហាញពីទិន្នន័យដែលទទួលបានពីទីតាំងត្រួតពិនិត្យ ។ ដោយសារឃើញមានកំហុសក្នុងទិន្នន័យនោះ វាជាការចាំបាច់ក្នុងការពិនត្យទិន្នន័យមុនពេលប្រើវា ។ លទ្ធផលនៃការពិនិត្យមានបង្ហាញក្នុងតារាង ៤.៥ ។




**រូបភាព ៤.៧:** ការពិនិត្យលើទិន្នន័យនៃការសង្កេតលើកំពស់ទឹកក្រោមដី (WT-4)

ដូចមានបង្ហាញក្នុងរូបភាពខាងលើ លទ្ធផលនៃការសង្កេតបានបង្ហាញថា រយៈពេលនៃទិន្នន័យ ដែលអាចទុកចិត្តបាន សំរាប់ទីតាំងត្រួតពិនិត្យ WT-4 មានកំណត់ពី ខែមិនា ឆ្នាំ២០០៧ ដល់ ខែមិនា ឆ្នាំ២០០៨ ។

### ទីតាំងត្រួតពិនិត្យ WT-5

រូបភាពខាងក្រោម បង្ហាញពីទិន្នន័យត្រួតពិនិត្យ ទទួលបានពីអណ្ដូងត្រួតពិនិត្យ WT-5 ដែលបង្ហាញពីទំនាក់ទំនងគ្នាពីរ នៃទំរង់ប្រែប្រួលទឹកក្រោមដី ។ ការប្រែប្រួលនៃទឹកក្រោមដី គឺមានក្នុងកំរិតពី២ម ទៅ ៧ម ក្រោមផ្ទៃដី មុនខែវិច្ឆិកា ឆ្នាំ២០០៥ និងក្នុងកំរិតមួយទៀត ពី១ម ទៅ ៤ម ក្រោយខែមិនា ឆ្នាំ២០០៦ ។




**រូបភាព ៤.៨:** លទ្ធផលនៃការសង្កេតលើការប្រែប្រួលកំពស់ទឹកក្រោមដី (WT-5)

ក្រាហ្វិកខាងលើបង្ហាញពីទិន្នន័យដែលទទួលបានពីទីតាំងត្រួតពិនិត្យ ។ ដោយសារឃើញមានកំហុសក្នុងទិន្នន័យនោះ វាចាការចាំបាច់ក្នុងការពិនត្យទិន្នន័យមុនពេលប្រើវា ។ លទ្ធផលនៃការពិនិត្យមានបង្ហាញក្នុងតារាង ៤.៥ ។




**រូបភាព ៤.៩:** ការពិនិត្យលើទិន្នន័យនៃការសង្កេតលើកំពស់ទឹកក្រោមដី (WT-5)

ដូចមានបង្ហាញក្នុងរូបភាពខាងលើ លទ្ធផលនៃការសង្កេតបានបង្ហាញថា រយះពេលនៃទិន្នន័យ ដែលអាចទុកចិត្តបាន សំរាប់តីតាំងត្រួតពិនិត្យ WT-5 មានកំណត់ពី ខែមិនា ឆ្នាំ២០០៧ ដល់ ខែមិនា ឆ្នាំ២០០៨ ។ ទោះចាយ៉ាងណាក៏ដោយ នៅពេលទិន្នន័យដែលទុកចិត្តបានទាំងនោះ ត្រូវបានប្រើសំរាប់វិភាគ ត្រូវមានការយកចិត្តទុកដាក់ ព្រោះថាទិន្នន័យដែលមិនត្រូវខ្លះនៅតែមាននៅក្នុងរយះពេលនោះ ។

### ទីតាំងត្រួតពិនិត្យ WT-6

រូបភាពខាងក្រោម បង្ហាញពីទន្នន័យត្រួតពិនិត្យទទួលបានពីអណ្តូងត្រួតពិនិត្យ WT-6 ។ ទឹកក្រោមដីប្រែប្រួលក្នុងកំរិតពី៩ម លើផ្ទៃដី ទៅ ៣ម ក្រោមផ្ទៃដី ។ យើងពិតជាឃើញច្បាស់ថា លទ្ធផលដែលថា កំពស់ទឹកក្រោមដី ៩ម លើផ្ទៃដីវាពិតជា មិនត្រឹមត្រូវ ។




**រូបភាព ៤.១០:** លទ្ធផលនៃការសង្កេតលើការប្រែប្រួលកំពស់ទឹកក្រោមដី (WT-6)

ក្រាហ្វិកខាងលើបង្ហាញពីទិន្នន័យដែលទទួលបានពីទីតាំងត្រួតពិនិត្យ ។ ដោយសារឃើញមានកំហុសក្នុងទិន្នន័យនោះ វាចាការចាំបាច់ក្នុងការពិនត្យទិន្នន័យមុនពេលប្រើវា ។ លទ្ធផលនៃការពិនិត្យមានបង្ហាញក្នុងតារាង ៤.៥ ។

ដូចមានបង្ហាញក្នុងរូបភាពខាងក្រោម លទ្ធផលនៃការសង្កេតបានបង្ហាញថា រយៈពេលនៃទិន្នន័យ ដែលអាចទុកចិត្តបាន សំរាប់តីតាំងត្រួតពិនិត្យ WT-6 មានកំណត់ពី ខែកក្កដា ឆ្នាំ២០០៨ ដល់ ខែមិថុនា ឆ្នាំ២០០៩ ។




**រូបភាព ៤.១១:** ការពិនិត្យលើទិន្នន័យនៃការសង្កេតលើកំពស់ទឹកក្រោមដី (WT-6)

**ទីតាំងត្រួតពិនិត្យ WT-7**

រូបភាពខាងក្រោម បង្ហាញពីទន្នន័យត្រួតពិនិត្យទទួលបានពីអណ្តូងត្រួតពិនិត្យ WT-7 ។ កំពស់ទឹកក្រោមដី នៅទីតាំងអណ្តូងត្រួតពិនិត្យ ជួនកាលមានកំពស់ខ្ពស់ជាងផ្ទៃដី ។ ទោះជាយ៉ាងណាក៏ដោយ រូបថតនៅក្នុងរូបភាព៤.១៣ បង្ហាញថា កំពស់ទឹកក្រោមដី មានប្រហែល ១០សម ខ្ពស់ជាងផ្ទៃដី នៅពេលដែលទីតាំងអណ្តូងត្រូវបានពិនិត្យ នៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០៩ ។ ជាងនោះទៅទៀត ភក់ដែលមាននៅសល់ក្នុងបំពង់អណ្តូង បានបង្ហាញថា កំពស់ទឹកក្រោមដីមានខ្ពស់ជាងផ្ទៃដីដល់ទៅ ២០សម ។ ដូចនេះ យើងអាចសន្និដ្ឋានបានថា ទិន្នន័យកត់ត្រាការប្រែប្រួលកំពស់ទឹកក្រោមដីនោះ គឺត្រឹមត្រូវ ។ រូបភាពបានបង្ហាញពីទំរង់ប្រែប្រួលទឹកក្រោមដីដែលមានជាប្រចាំមួយ លើកលែងតែមានកហុសក្នុងការកត់ត្រាទិន្នន័យខ្លះតែប៉ុណ្ណោះ ។




**រូបភាព ៤.១២:** លទ្ធផលនៃការសង្កេតលើការប្រែប្រួលកំពស់ទឹកក្រោមដី (WT-7)

ក្រាហ្វិកខាងលើបង្ហាញពីទិន្នន័យដែលទទួលបានពីទីតាំងត្រួតពិនិត្យ ។ ដោយសារឃើញមានកំហុសក្នុងទិន្នន័យនោះ វាចាការចាំបាច់ក្នុងការពិនត្យទិន្នន័យមុនពេលប្រើវា ។ លទ្ធផលនៃការពិនិត្យមានបង្ហាញក្នុងតារាង ៤.៥ ។



**រូបភាព ៤.១៣:** រូបថតបន្ទប់ត្រួតពិនិត្យនៃទីតាំងត្រួតពិនិត្យ WT-7

យើងឃើញមានភាពទំនាក់ទំនងគ្នាយ៉ាងខ្លាំង រវាងទិន្នន័យទាំងពីរ នៅក្នុងរយៈពេលនៃការពិនិត្យដែលទាក់ទងទាំងមូល ។ ព្រោះថា រូបភាព៤.១២ បានបង្ហាញពីការប្រែប្រួលកំពស់ទឹកក្រោមដី នៅក្នុងទីតាំងនេះដែលលទ្ធផលនៃអណ្តូងត្រួតពិនិត្យ WT-7 មាន ។




**រូបភាព ៤.១៤:** ការពិនិត្យលើទិន្នន័យនៃការសង្កេតលើកំពស់ទឹកក្រោមដី (WT-7)

**ទីតាំងត្រួតពិនិត្យ WT-8**

រូបភាពខាងក្រោម បង្ហាញពីទន្នន័យត្រួតពិនិត្យទទួលបានពីអណ្តូងត្រួតពិនិត្យ WT-8 ។ ឧបករណ៍សង្កេតដោយស្វ័យប្រវត្តិ ត្រូវបានតំឡើងនៅទីតាំងនេះក្នុងឆ្នាំ ២០០៣ ។ ទោះជាយ៉ាងណាក៏ដោយ ឧបករណ៍នោះ ត្រូវបានបាត់ ក្នុងរយៈពេលក្រោយពីការតំឡើងនោះ ។ ដូចនេះ ទិន្នន័យសំរាប់អណ្តូង មានតែពី ខែសីហា ឆ្នាំ២០០៣ ទៅដល់ខែមករា ឆ្នាំ២០០៤ ។




**រូបភាព ៤.១៥:** លទ្ធផលនៃការសង្កេតលើការប្រែប្រួលកំពស់ទឹកក្រោមដី (WT-8)

ក្រាហ្វិកខាងលើ បង្ហាញពីទិន្នន័យដែលទទួលបានពីទីតាំងត្រួតពិនិត្យWT-8 ។ ដោយសារឃើញមានកំហុសក្នុងទិន្នន័យនោះ វាជាការចាំបាច់ក្នុងការពិនត្យទិន្នន័យមុនពេលប្រើវា ។ លទ្ធផលនៃការពិនិត្យមានបង្ហាញក្នុងតារាង៤.៥ ។

### ទីតាំងត្រួតពិនិត្យទឹកក្រោមដី និងការផ្លាស់ប្តូរដី LTa

ទីតាំងត្រួតពិនិត្យ **LTa** គឺមិនមែនតែសំរាប់ការពិនិត្យលើទឹកក្រោមដី តែប៉ុណ្ណោះទេ ប៉ុន្តែសំរាប់ត្រួតពិនិត្យលើការស្រុតដីផងដែរ ។ អណ្តូងត្រួតពិនត្យពីរត្រូវបានខួងដាក់នៅក្នុងទីតាំងតែមួយ សំរាប់ត្រួតពិនិត្យលើទឹកក្រោមដី និងលើការផ្លាស់ប្តូរដី នៅក្នុងស្រទាប់ដែលមានទឹករាក់ និងជ្រៅ ផ្សេងៗគ្នា ។ រូបភាពខាងក្រោម បង្ហាញពីទន្នន័យត្រួតពិនិត្យលើកំពស់ទឹកក្រោមដី សំរាប់ស្រទាប់ដែលមានទឹករាក់ និងជ្រៅ នៅក្នុងទីតាំងអណ្តូងត្រួតពិនិត្យ LTa ។




**រូបភាព ៤.១៦:** លទ្ធផលនៃការពិនិត្យនៃការប្រែប្រួលកំពស់ទឹកក្រោមដី **(LTa)**

ក្រាហ្វិកខាងលើ បង្ហាញពីទិន្នន័យដែលទទួលបាន ពីទីតាំងត្រួតពិនិត្យ LTa។ ដោយសារឃើញមានកំហុសក្នុងទិន្នន័យ នោះ វាជាការចាំបាច់ក្នុងការពិនត្យទិន្នន័យ មុនពេលប្រើវា។ លទ្ធផលនៃការពិនិត្យ មានបង្ហាញក្នុងតារាង ៤.៥ ។

ចាប់ពីខែសីហា ឆ្នាំ២០០៣ ដល់ខែសីហា ឆ្នាំ២០០៦ លទ្ធផល អាចចាត់ទុកថា បានកត់ត្រាត្រឹមត្រូវ ដើម្បីបង្ហាញយ៉ាងច្បាស់ នូវភាពខុសគ្នានៃការប្រែប្រួលទឹកក្រោមដី រវាងស្រទាប់ដែលមានទឹកភាក់ និងជ្រៅ ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផល ហាក់ដូចជាមានភាពច្រលំបល់ ចាប់ពីខែសីហា ឆ្នាំ២០០៦ ដល់ខែកញ្ញា ឆ្នាំ២០០៨ រួមទាំងរយៈពេលដែលមិនបានកត់ត្រាទិន្នន័យ ប្រហែលមួយឆ្នាំទៀតផង ។ ក្រោយរយៈពេលដែលមិនបានកត់ត្រាទិន្នន័យ ទំរង់នៃការប្រែប្រួលនៃស្រទាប់ដែលមានទឹកភាក់ និងជ្រៅ ហាក់ដូចជាមានភាពផ្ទុយគ្នាទាំងស្រុង ដែលបង្ហាញពីបញ្ហានៃការភ្ជាប់ផ្ទុយគ្នានៃគ្រឿងទទួល និងប្រអប់ផ្ទុកទិន្នន័យ ។




**រូបភាព ៤.១៧:** លទ្ធផលនៃការសង្កេតដោយដៃនៅទីតាំងពិនិត្យ LTa

ដូចមានបង្ហាញនៅក្នុងរូបភាពខាងលើ ការសង្កេតដោយដៃ បានផ្តល់នូវចំលើយដូចគ្នាទៅនឹងការសង្កេតដោយស្វ័យប្រវត្តិដែរ ដែលថា ទំរង់នៃការប្រែប្រួលកំពស់ទឹកក្រោមដី បានផ្លាស់ប្តូរយ៉ាងខ្លាំង ក្នុងឆ្នាំ២០០៨ ។ មូលហេតុដែលអាចសន្និតបាន ចំពោះលទ្ធផលនេះ គឺថា ក្រោយរយៈពេលដែលមិនបានកត់ត្រាទិន្នន័យ (ពីខែមិនា ឆ្នាំ២០០៨ ដល់ខែមិថុនា ឆ្នាំ២០០៨) លេខរៀងអណ្តូងខុស ត្រូវបានកត់ត្រា នៅលើក្រដាសត្រួតពិនិត្យដោយដៃ ។

ទោះបីជាទិន្នន័យត្រូវបានរៀបចំឡើងវិញក៏ដោយ ការពិនិត្យដោយប្រៀបធៀប រវាងទិន្នន័យទាំងពីរ នៅតែផ្តល់នូវទំនាក់ទំនងមួយ ដែលមិនអាចទទួលយកបាន ដូចមានបង្ហាញក្នុងរូបភាពទាំងពីរខាងក្រោម ។ ដូចនេះ ទិន្នន័យត្រួតពិនិត្យទឹកក្រោមដី ក្នុងទីតាំងអណ្តូង LTa ត្រូវតែចាត់ទុកជាមិនបានការ សំរាប់ការវិភាគ ។




**រូបភាព ៤.១៨:** ការពិនិត្យលើទិន្នន័យសង្កេតកំពស់ទឹកក្រោមដី ( LTa ស្រទាប់ដែលមានទឹកជ្រៅ)




**រូបភាព ៤.១៩:** ការពិនិត្យលើទិន្នន័យសង្កេតកំពស់ទឹកក្រោមដី ( LTa ស្រទាប់ដែលមានទឹករាក់)

### ទីតាំងពិនិត្យកំពស់ទឹកក្រោមដី LTb

អណ្តូងចំនួនពីរ ក៏ត្រូវបានខួងផងដែរក្នុងទីតាំង LTb សំរាប់ការសង្កេតលើកំពស់ទឹកក្រោមដី និងការប្រែប្រួលដី ក្នុងស្រទាប់ដែលមានទឹករាក់ និងជ្រៅផ្សេងៗគ្នា ។ រូបភាពខាងក្រោម បង្ហាញពីទិន្នន័យនៃកំពស់ទឹកក្រោមដី ក្នុងស្រទាប់ដែលមានទឹករាក់ និងជ្រៅ ក្នុងទីតាំងនោះ ។

យើងអាចឃើញមានផងដែរ នូវភាពទាក់ទងគ្នាខ្លាំង រវាងរូបភាព៤.២១ និង៤.២២ ចំពោះការបញ្ជាក់នូវភាពអាចជឿទុកចិត្តបាន នៃលទ្ធផលនៃការសង្កេតលើទឹកក្រោមដី ក្នុងស្រទាប់ដែលមានទឹកទាំងពីរ ។ គ្រប់ទិន្នន័យទាំងអស់ ក្នុងទីតាំង LTb នេះ អាចចាត់ទុកថា អាចទុកចិត្តបាន សំរាប់ការវិភាគទឹកក្រោមដី ។




**រូបភាព ៤.២០:** លទ្ធផលនៃការពិនិត្យនៃការប្រែប្រួលកំពស់ទឹកក្រោមដី (LTb)

ក្រាហ្វិកខាងលើ បង្ហាញពីទិន្នន័យដែលទទួលបាន ពីទីតាំងត្រួតពិនិត្យ LTb ។ ដោយសារឃើញមានកំហុសក្នុងទិន្នន័យ នោះ វាជាការចាំបាច់ក្នុងការពិនត្យទិន្នន័យ មុនពេលប្រើវា ។ លទ្ធផលនៃការពិនិត្យ មានបង្ហាញក្នុងតារាង ៤.៥ ។

តាមការពិនិត្យលទ្ធផលនៃការត្រួតពិនិត្យលើការប្រែប្រួលទឹកក្រោមដី ដូចមានបង្ហាញក្នុងរូបភាពខាងលើ យើងអាចទាញសេចក្តីសន្និដ្ឋានបានដូចខាងក្រោម ។

### ១) ទំរង់នៃការប្រែប្រួលកំពស់ទឹកក្រោមដី

ទាំងស្រទាប់ដែលមានទឹករាក់ និងជ្រៅ មានទំរង់នៃការប្រែប្រួលទឹកក្រោមដីដូចគ្នា ។ កំពស់ទឹកក្រោមដីកើនឡើង នៅក្នុងរដូវវស្សា និងស្រកចុះ នៅក្នុងរដូវប្រាំង ។

### ២) ភាពខុសគ្នារវាងកំពស់ទឹកនៅក្នុងស្រទាប់ដែលមានទឹកទាំងពីរ

តំលៃនៃកំពស់ទឹកក្រោមដី នៅក្នុងស្រទាប់ដែលមានទឹកទាំងពីរ គឺមានភាពខុសគ្នា ស្ទើរតែពេញកំលុងពេលនៃការពិនិត្យទាំងមូល ។ ប្រការដែលច្បាស់នោះគឺថា បើប្រៀបធៀបទៅនឹងស្រទាប់ដែលមានទឹកជ្រៅ ស្រទាប់ដែលមានទឹករាក់ មានខ្ពស់ជាង នៅក្នុងរដូវវស្សា ប៉ុន្តែមានទាបជាង នៅក្នុងរដូវប្រាំង ។

ទឹកហូរពីទីខ្ពស់ទៅទីទាប ។ ដូចនេះ ប្រសិនបើមានការហូរទឹករវាងស្រទាប់ដែលមានទឹករាក់ និងជ្រៅនោះ ទិសដៅរបស់រំហូរទឹកក្រោមដី នឹងផ្លាស់ប្តូរដូចតទៅៈ ១)- ហូរចុះក្រោម ពីស្រទាប់ដែលមានទឹករាក់ ទៅស្រទាប់ដែលមានទឹកជ្រៅ នៅក្នុងរដូវវស្សា និង ២)-ហូរឡើងលើ ពីស្រទាប់ដែលមានទឹកជ្រៅ ទៅស្រទាប់ដែលមានទឹករាក់ នៅក្នុងរដូវប្រាំង ។

### ៣) គំរិតនៃការប្រែប្រួលកំពស់ទឹក

ដូចមានបង្ហាញក្នុងរូបភាព៤.២០ ស្ទើរតែពេញរយៈពេលនៃការសង្កេតទាំងមូល កំពស់ទឹកនៅក្នុងស្រទាប់ដែលមានទឹកជ្រៅ គឺខុសពីនៅស្រទាប់ដែលមានទឹករាក់ ។ ហើយកំពស់ទឹកនៅក្នុងស្រទាប់ដែលមានទឹកជ្រៅ មិនដែលមានដល់គំរិតខ្ពស់បំផុត ឬធ្លាក់ចុះដល់ទាបបំផុត ដូចក្នុងស្រទាប់ដែលមានទឹករាក់ទេ ។ ករណីនេះ បានបង្ហាញថា ស្រទាប់ទឹករាក់ និងជ្រៅ គឺមានភាពទាក់ទងទៅនឹងប្រព័ន្ធស្រទាប់ទឹកផ្សេងៗគ្នា ។




**រូបភាព ៤.២១:**ការពិនិត្យលើទិន្នន័យសង្កេតកំពស់ទឹកក្រោមដី (LTb ស្រទាប់ដែលមានទឹកជ្រៅ)




**រូបភាព ៤.២២:** ការពិនិត្យលើទិន្នន័យសង្កេតកំពស់ទឹកក្រោមដី (LTb ស្រទាប់ដែលមានទឹករាក់)

## ៤-៤-៣ លទ្ធផលនៃការពិនិត្យលើការប្រែប្រួលដី

**លទ្ធផលនៃការពិនិត្យលើការប្រែប្រួលដីនៅទីតាំង LTa**

រូបភាពខាងក្រោម បង្ហាញពីលទ្ធផលនៃការត្រួតពិនិត្យ លើការប្រែប្រួលដី នៅស្រទាប់ដែលមានទឹករាក់ និងជ្រៅ នៅទីតាំងអណ្តូង LTa ។




**រូបភាព ៤.២៣:** លទ្ធផលនៃការត្រួតពិនិត្យលើការប្រែប្រួលដី នៅទីតាំងអណ្តូង LTa

លើកលែងតែចំពោះទិន្នន័យត្រួតពិនិត្យដែលមានកំហុសជាក់ស្តែង ដែលកត់ត្រាពីខែវិច្ឆិកា ដល់ ខែកក្កដា ឆ្នាំ២០០៨ នោះចេញ លទ្ធផលនៃការសង្កេតបានបង្ហាញនូវចំណុចដូចខាងក្រោម:

-ការប្រែប្រួលដីត្រូវបានសង្កេតទាំងនៅក្នុងស្រទាប់ដែលមានទឹករាក់ និងជ្រៅ ។

-ទំរង់នៃការប្រែប្រួលដី នៅក្នុងស្រទាប់ដែលមានទឹកទាំងពីរមានដូចគ្នា ។

-ការប្រែប្រួលដី គឺមានភាពស្របគ្នា ជាមួយនឹងការប្រែប្រួលកំពស់ទឹកក្រោមដី ហើយប្រែប្រួលទៅតាមរដូវ ។

ដើម្បីបញ្ជាក់ពីទំនោរនៃការប្រែប្រួលដី គឺនៅក្នុងវដ្តនៃបម្រែបម្រួលរដូវ តម្លៃប្រែប្រួលមធ្យម ប្រចាំខែ ត្រូវបានគណនា ។ ដូចបានបង្ហាញក្នុងតារាងខាងក្រោម ការពិនិត្យលើទិន្នន័យដែលបានបង្ហាញថា កម្រិតប្រែប្រួលអតិបរមាពី ១៨.៩៦-១៧.០៦ = ១.៩មីលីម៉ែត្រ ចំពោះស្រទាប់ដែលមានទឹកជ្រៅ ។

**តារាង ៤.១:** លទ្ធផលសង្ខេបប្រចាំខែ នៃតំលៃវាស់វែង នៅស្ថានីយ៍វាស់ការប្រែប្រួលដី ក្នុងស្រទាប់ដីដែលមានទឹកជ្រៅ LTa (mm)

| Month | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | Max. | Min. | Avrg, |
|---|---|---|---|---|---|---|---|---|---|---|
| Jan. | -- | 18.21 | 18.12 | 18.20 | -- | -- | 18.03 | 18.21 | 18.03 | 18.15 |
| Feb. | -- | 17.99 | 17.88 | 17.98 | -- | -- | 17.76 | 17.99 | 17.76 | 17.92 |
| Mar. | -- | 17.76 | 17.64 | 17.80 | -- | -- | 17.57 | 17.80 | 17.57 | 17.71 |
| Apr. | -- | 17.50 | 17.30 | 17.72 | -- | -- | -- | 17.72 | 17.30 | 17.56 |
| May | -- | 17.24 | 17.06 | 17.61 | -- | -- | 17.33 | 17.61 | 17.06 | 17.37 |
| Jun. | -- | 18.07 | 17.09 | 17.59 | -- | -- | 17.37 | 18.07 | 17.09 | 17.64 |
| Jul. | -- | 18.55 | 17.06 | 17.77 | -- | -- | -- | 18.55 | 17.06 | 17.98 |
| Aug. | 18.14 | 18.87 | 17.11 | 18.01 | -- | -- | -- | 18.87 | 17.11 | 18.20 |
| Sep. | 18.26 | 18.96 | 17.82 | 18.21 | -- | -- | -- | 18.96 | 17.82 | 18.44 |
| Oct. | 18.49 | 18.91 | 18.59 | 18.67 | -- | 18.21 | -- | 18.91 | 18.21 | 18.63 |
| Nov. | 18.60 | 18.64 | 18.71 | 18.60 | -- | 18.52 | -- | 18.71 | 18.52 | 18.63 |
| Dec. | 18.42 | 18.38 | 18.47 | -- | -- | 18.27 | -- | 18.47 | 18.27 | 18.40 |
| Max. | 18.60 | 18.96 | 18.71 | 18.67 | | 18.52 | 18.03 | 18.96 | | |
| Min. | 18.14 | 17.24 | 17.06 | 17.59 | | 18.21 | 17.33 | | 17.06 | |
| Avrg, | 18.38 | 18.26 | 17.74 | 18.01 | | 18.33 | 17.61 | | | 18.02 |

<u>**សំគាល់**</u>: តំលៃវាស់នេះ មិនបង្ហាញផ្ទាល់ពីតំលៃនៃការប្រែប្រួលដីទេ ប៉ុន្តែគ្រាន់តែជាកំរិតតំលៃក្នុងលក្ខខ័ណ្ឌ ។

កម្រិតប្រែប្រួលដីអតិបរមា នៅក្នុងស្រទាប់ដែលមានទឹករាក់ គឺ ១៦.៣១-១៣.៨៦=២.៤៥មីលីម៉ែត្រ ដូចបានបង្ហាញក្នុងតារាងខាងក្រោម ។

**តារាង ៤.២:** លទ្ធផលសង្ខេបប្រចាំខែ នៃតំលៃវាស់វែង នៅស្ថានីយ៍វាស់ការប្រែប្រួលដី ក្នុងស្រទាប់ដីដែលមានទឹករាក់ LTa (mm)

| Month | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | Max. | Min. | Avrg, |
|---|---|---|---|---|---|---|---|---|---|---|
| Jan. | -- | 15.59 | 15.47 | 15.56 | -- | -- | 15.37 | 15.59 | 15.37 | 15.52 |
| Feb. | -- | 15.31 | 15.24 | 15.36 | -- | -- | 15.20 | 15.36 | 15.20 | 15.29 |
| Mar. | -- | 15.00 | 14.85 | 15.22 | -- | -- | 15.00 | 15.22 | 14.85 | 15.06 |
| Apr. | -- | 14.63 | 14.24 | 15.11 | -- | -- | -- | 15.11 | 14.24 | 14.77 |
| May | -- | 14.30 | 13.86 | 14.96 | -- | -- | 14.69 | 14.96 | 13.86 | 14.55 |
| Jun. | -- | 15.37 | 14.07 | 14.93 | -- | -- | 14.72 | 15.37 | 14.07 | 14.89 |
| Jul. | -- | 15.89 | 14.04 | 15.16 | -- | -- | -- | 15.89 | 14.04 | 15.25 |
| Aug. | 15.69 | 16.20 | 14.01 | 15.43 | -- | -- | -- | 16.20 | 14.01 | 15.51 |
| Sep. | 15.76 | 16.31 | 14.96 | 15.65 | -- | -- | -- | 16.31 | 14.96 | 15.80 |
| Oct. | 15.96 | 16.26 | 15.89 | 16.09 | -- | 15.64 | -- | 16.26 | 15.64 | 16.02 |
| Nov. | 15.99 | 16.00 | 16.03 | 16.02 | -- | 15.88 | -- | 16.03 | 15.88 | 15.99 |
| Dec. | 15.78 | 15.72 | 15.78 | -- | -- | 15.60 | -- | 15.78 | 15.60 | 15.73 |
| Max. | 15.99 | 16.31 | 16.03 | 16.09 | -- | 15.88 | 15.37 | 16.31 | | |
| Min. | 15.69 | 14.30 | 13.86 | 14.93 | -- | 15.60 | 14.69 | | 13.86 | |
| Avrg, | 15.84 | 15.53 | 14.79 | 15.41 | -- | 15.76 | 15.00 | | | 15.33 |

***សំគាល់***: តំលៃវាស់នេះ មិនបង្ហាញផ្ទាល់ពីតំលៃនៃការប្រែប្រួលដីទេ ប៉ុន្តែគ្រាន់តែជាគិរិតតំលៃក្នុងលក្ខខ័ណ្ឌ ។

នៅពេលដែលយើងប្រៀបធៀបតារាងទាំងពីរខាងលើនោះ គឺយើងឃើញថា លទ្ធផលវាហាក់ដូចជាមិនប្រក្រតី ។ នៅពេលដែលការប្រែប្រួលដី ត្រូវបានពិនិត្យ នៅក្នុងស្រទាប់ដែលមានទឹកជ្រៅ និងរាក់ នៅក្នុងទីតាំងតែមួយនោះ ជាទូទៅ ការប្រែប្រួលដី នៅក្នុងស្រទាប់ដែលមានទឹកជ្រៅ គឺមានច្រើនជាង នៅក្នុងស្រទាប់ដែលមានទឹករាក់ ឬ យ៉ាងហោចណាស់ដូចគ្នា ទៅនឹងស្រទាប់ដែលមានទឹករាក់ ។

លទ្ធភាពពីរ ដែលយើងអាចសន្និដ្ឋានថា ជាមូលហេតុនៃបញ្ហានេះ ១) ភាពសុក្រឹត្យរបស់ឧបករណ៍មិនមានខ្ពស់គ្រប់គ្រាន់ សម្រាប់ការប្រែប្រួលដី ដែលមានកម្រិតតិច ២) ទិន្នន័យត្រូវបានកត់ត្រា ក្នុងប្រព័ន្ធទិន្នន័យខុស ។ គឺមានន័យថា លទ្ធផលនៃការសង្កេតលើស្រទាប់ដែលមានទឹកជ្រៅ ត្រូវបានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យនៃស្រទាប់ដែលមានទឹករាក់ ។

រូបភាពខាងក្រោមបង្ហាញ ពីការប្រែប្រួលដីជាមធ្យមប្រចាំឆ្នាំ នៅទីតាំងអណ្តូងត្រួតពិនិត្យ LTa ។ ក្នុងរយះពេល នៃការពិនិត្យ៦ឆ្នាំ វាអាចពិបាកក្នុងការសន្និដ្ឋានថា ការស្រុតដីបានកើតមានរួចទៅហើយ ឬយ៉ាងណាបើទោះជាមាន សញ្ញាខ្លះនៃការស្រុតដី ដូចដែលបានបង្ហាញក្នុងរូបភាពខាងក្រោមទាំងនេះក៏ដោយ។




**រូបភាព ៤.២៤:** ការប្រែប្រួលដីប្រចាំឆ្នាំ ក្នុង LTa

## លទ្ធផលនៃការសង្កេតលើការប្រែប្រួលដី ក្នុងអណ្តូង LTb

រូបភាពខាងក្រោមបង្ហាញពីលទ្ធផលនៃការពិនិត្យលើការប្រែប្រួលដីនៅអណ្តូង LTb ។ ការពិនិត្យនៅទីតាំងអណ្តូង LTb បានចាប់ផ្តើមតាំងពីខែកក្កដា ឆ្នាំ២០០៣ ។ ទិន្នន័យរយៈពេល៦ឆ្នាំ ត្រូវបានប្រមូលរហូតដល់ខែកក្កដា ឆ្នាំ២០០៩ ។ ដូចបានបង្ហាញក្នុងរូបភាព ការប្រែប្រួលដី ត្រូវបានចាត់ទុកថា បានពិនិត្យត្រឹមត្រូវ លើកលែងតែមានកំហុសខ្លះ និងមានការបាត់បង់ទិន្នន័យរយៈពេល៦ខែ ចាប់តាំងពីខែមិនា ដល់ខែកញ្ញា ឆ្នាំ២០០៨ ។




**រូបភាព ៤.២៥:** លទ្ធផលនៃការសង្កេតលើការប្រែប្រួលដី ក្នុងអណ្តូងLTa

ការប្រែប្រួលដីមធ្យមប្រចាំខែ នៅក្នុងស្រទាប់ដែលមានទឹកជ្រៅ និងរាក់ត្រូវបានគណនា និងបង្ហាញក្នុង តារាង ៤.៣ និង៤.៤ ដោយឡែកពីគ្នា ។

**តារាង ៤.៣:** លទ្ធផលសង្ខេបប្រចាំខែ នៃតំលៃវាស់វែង នៅស្ថានីយ៍វាស់ការប្រែប្រួលដី ក្នុងស្រទាប់ដីដែលមានទឹកជ្រៅ LTb (mm)

| Month | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | Max. | Min. | Avrg, |
|---|---|---|---|---|---|---|---|---|---|---|
| Jan. | -- | 32.71 | 32.39 | 32.56 | 32.62 | 32.62 | 31.93 | 32.71 | 31.93 | 32.51 |
| Feb. | -- | 32.45 | 32.20 | 32.40 | 32.37 | 32.43 | 31.80 | 32.45 | 31.80 | 32.30 |
| Mar. | -- | 32.09 | 31.94 | 32.26 | 32.16 | 32.23 | 31.65 | 32.26 | 31.65 | 32.08 |
| Apr. | -- | 31.79 | 31.66 | 32.16 | 31.97 | -- | 31.55 | 32.16 | 31.55 | 31.88 |
| May | -- | 31.81 | 31.47 | 32.01 | 32.07 | -- | 31.62 | 32.07 | 31.47 | 31.84 |
| Jun. | -- | 32.56 | 31.40 | 32.08 | 32.24 | -- | 31.62 | 32.56 | 31.40 | 32.08 |
| Jul. | -- | 32.99 | 31.47 | 32.27 | 32.45 | -- | -- | 32.99 | 31.47 | 32.43 |
| Aug. | 32.44 | 33.36 | 31.69 | 32.41 | 32.59 | -- | -- | 33.36 | 31.69 | 32.64 |
| Sep. | 32.70 | 33.31 | 32.01 | 32.71 | 32.84 | -- | -- | 33.31 | 32.01 | 32.81 |
| Oct. | 33.07 | 33.06 | 32.44 | 33.11 | 32.97 | 32.49 | -- | 33.11 | 32.44 | 32.89 |
| Nov. | 32.99 | 32.84 | 32.68 | 33.00 | 32.91 | 32.28 | -- | 33.00 | 32.28 | 32.81 |
| Dec. | 32.97 | 32.59 | 32.66 | 32.83 | 32.80 | 32.09 | -- | 32.97 | 32.09 | 32.70 |
| Max. | 33.07 | 33.36 | 32.68 | 33.11 | 32.97 | 32.62 | 31.93 | 33.36 | | |
| Min. | 32.44 | 31.79 | 31.40 | 32.01 | 31.97 | 32.09 | 31.55 | | 31.40 | |
| Avrg, | 32.83 | 32.62 | 32.01 | 32.49 | 32.49 | 32.36 | 31.71 | | | 32.37 |

**សំគាល់:** តំលៃវាស់នេះ មិនបង្ហាញផ្ទាល់ពីតំលៃនៃការប្រែប្រួលដីទេ ប៉ុន្តែគ្រាន់តែជាកំរិតតំលៃក្នុងលក្ខខ័ណ្ឌ ។

**តារាង ៤.៤:** លទ្ធផលសង្ខេបប្រចាំខែ នៃតំលៃវាស់វែង នៅស្ថានីយ៍វាស់ការប្រែប្រួលដី ក្នុងស្រទាប់ដីដែលមានទឹករាក់ LTb (mm)

| Month | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | Max. | Min. | Avrg, |
|---|---|---|---|---|---|---|---|---|---|---|
| Jan. | -- | 31.37 | 30.57 | 30.62 | 30.23 | 29.53 | 28.35 | 31.37 | 28.35 | 30.29 |
| Feb. | -- | 31.10 | 30.32 | 30.39 | 30.09 | 29.31 | 28.02 | 31.10 | 28.02 | 30.05 |
| Mar. | -- | 30.67 | 30.04 | 30.30 | 29.94 | 29.11 | 27.76 | 30.67 | 27.76 | 29.78 |
| Apr. | -- | 30.30 | 29.77 | 30.20 | 30.01 | -- | 27.59 | 30.30 | 27.59 | 29.70 |
| May | -- | 30.37 | 29.57 | 29.98 | 29.96 | -- | 27.64 | 30.37 | 27.64 | 29.65 |
| Jun. | -- | 31.22 | 29.52 | 30.10 | 29.89 | -- | 27.58 | 31.22 | 27.58 | 29.92 |
| Jul. | -- | 31.56 | 29.71 | 30.32 | 29.85 | -- | -- | 31.56 | 29.71 | 30.60 |
| Aug. | 31.47 | 31.75 | 30.00 | 30.39 | 29.86 | -- | -- | 31.75 | 29.86 | 30.87 |
| Sep. | 31.67 | 31.52 | 30.33 | 30.59 | 29.99 | -- | -- | 31.67 | 29.99 | 30.96 |
| Oct. | 31.89 | 31.22 | 30.67 | 30.77 | 30.01 | 28.88 | -- | 31.89 | 28.88 | 30.76 |
| Nov. | 31.29 | 30.95 | 30.84 | 30.51 | 29.98 | 28.75 | -- | 31.29 | 28.75 | 30.52 |
| Dec. | 31.66 | 30.74 | 30.82 | 30.34 | 29.67 | 28.39 | -- | 31.66 | 28.39 | 30.47 |
| Max. | 31.89 | 31.75 | 30.84 | 30.77 | 30.23 | 29.53 | 28.35 | 31.89 | | |
| Min. | 31.29 | 30.30 | 29.52 | 29.98 | 29.67 | 28.39 | 27.58 | | 27.58 | |
| Avrg, | 31.60 | 31.06 | 30.18 | 30.38 | 29.96 | 29.00 | 27.82 | | | 30.12 |

**សំគាល់**: តំលៃវាស់នេះ មិនបង្ហាញផ្ទាល់ពីតំលៃនៃការប្រែប្រួលដីទេ ប៉ុន្តែគ្រាន់តែជាគិតតំលៃក្នុងលក្ខខ័ណ្ឌ ។

រូបភាពខាងក្រោម បង្ហាញពីតំលៃមធ្យមប្រចាំឆ្នាំ នៃការប្រែប្រួលដី ក្នុងទីតាំងត្រួតពិនិត្យ LTb ។ ដូច លទ្ធផលក្នុងទីតាំង LTa ដែរ លទ្ធផលដែលបង្ហាញក្នុងរូបភាព អាចចាត់ទុកថាមិនប្រក្រតី ដោយសារថា បរិមាណ នៃការប្រែប្រួលក្នុងស្រទាប់ដីដែលមានទឹកជ្រៅ គឺតិចជាងក្នុងស្រទាប់ដីដែលមានទឹករាក់ ។ លទ្ធភាពនៃ ព្រឹត្តិការណ៍មិនប្រក្រតីនេះ អាចគិតថា វាជាមូលហេតុនៃបញ្ហា: គឺឧបករណ៍មិនមានភាពត្រឹមត្រូវខ្ពស់ល្អ សំរាប់សង្កេតលើការប្រែប្រួលដីតិច ។

ដោយសារមូលហេតុនៃភាពត្រឹមត្រូវទាប នៃឧបករណ៍វាស់វែង និងការមិនអាចមើលឃើញ ការប្រែប្រួលដី នៅទីតាំងសំណង់នានា វាត្រូវបានសន្និដ្ឋានថា មិនមានការស្រុតដីទេ ។ ទោះជាយ៉ាងណាក៏ដោយ ចាំបាច់ត្រូវបន្តត្រួតពិនិត្យលើទិន្នន័យសង្កេតលើការស្រុតដីចាប់ពីពេលនេះតទៅ ។




**រូបភាព ៤.២៦:** ការប្រែប្រួលដីប្រចាំឆ្នាំ ក្នុងអណ្តូង LTb

## ៤.៥-ការវិភាគលើការបំពេញមកវិញនូវទឹកក្រោមដី

### ៤.៥.១-ការពិនិត្យលើទិន្នន័យ

ទំនាក់ទំនងរវាងបរិមាណទឹកភ្លៀង និងការបំពេញទឹកក្រោមដីមកវិញ មានទំនាក់ទំនងទៅនឹងកត្តា ឋានលេខា ចំងាយពីកន្លែងធ្លាក់ភ្លៀងទៅទន្លេ លក្ខណៈភូគព្ភសាស្ត្រ ប្រភេទដី អាកាសធាតុ (រំហួត និងសំណើម) ការប្រើប្រាស់ដី ជម្រៅទឹកក្រោមដី និងកត្តាផ្សេងៗទៀត ។ ដើម្បីទទួលបាននូវតួលេខគ្រប់គ្រាន់ ចំពោះ ប៉ារ៉ាម៉ែត្រទាំងអស់នេះ ក្នុងខ្នាតប្រចាំថ្ងៃ គឺពិតជាមិនអាចមានទេ ។ ក្នុងចំណោមវិធីសាស្ត្រនានា សម្រាប់ការ វិភាគលើការបំពេញទឹកក្រោមដីមកវិញ ម៉ូដែលធុង អាចចាត់ទុកជាម៉ូដែលមួយល្អបំផុត ។ នៅពេលដែល បរិមាណនៃទឹកភ្លៀង និងរំហួតមានការទាក់ទងគ្នាផ្ទាល់ ទៅនឹងការប្រែប្រួលកំពស់ទឹកក្រោមដី តាមរយៈ ម៉ូដែល ធុង នោះ បរិមាណនៃការបំពេញមកវិញ និងការប្រើទឹកក្រោមដី អាចនឹងត្រូវគណនាជាសរុប នៃលទ្ធផល ដែលមានការទាក់ទងទៅនឹងកត្តាទាំងអស់នេះ ។ គោលគំនិតសំខាន់របស់ម៉ូដែលធុង មានបង្ហាញក្នុងរូបភាព ខាងក្រោម ។




A1:បរិមាណទឹកភ្លៀងអប្បបរមា ( មម) សំរាប់ការបំពេញមកវិញនូវទឹកក្រោមដី ។

A1:បរិមាណទឹកភ្លៀងអប្បបរមា ( មម) សំរាប់ការបំពេញមកវិញនូវទឹកក្រោមដី ។

A1:បរិមាណទឹកភ្លៀងអប្បបរមា ( មម) សំរាប់ការបំពេញមកវិញនូវទឹកក្រោមដី ។

F1:ច្រកហូរចេញពីអាង សំរាប់ការបំពេញមកវិញនូវទឹកក្រោមដី ។

F2:ច្រកហូរចេញពីអាង សំរាប់ទឹកដែលហូរលើផ្ទៃដី ។

F3:ច្រកហូរចេញពីអាង សំរាប់ទឹកដែលហូរលើផ្ទៃដីអតិបរមា ។

P1:មេគុណ សំរាប់ការបំពេញមកវិញនូវទឹកក្រោមដី ។

P2: មេគុណ សំរាប់ទឹកដែលហូរលើផ្ទៃដី ។

P3: មេគុណ សំរាប់ទឹកដែលហូរលើផ្ទៃដីអតិបរមា ។

**រូបភាព ៤.២៧:** គោលគំនិតសំខាន់របស់ម៉ូដែលធុង

ទំនាក់ទំនងរវាងស្ថានីយ៍ត្រួតពិនិត្យឧតុនិយម  និងទីតាំងត្រួតពិនិត្យទឹកក្រោមដី  មានបង្ហាញក្នុងរូបភាពខាងក្រោម ។




**រូបភាព ៤.២៨:** ទីតាំងនៃអណ្តូងត្រួតពិនិត្យទឹកក្រោមដី និងស្ថានីយឧតុនិយមក្នុងតំបន់សិក្សា

លទ្ធផលនៃការបញ្ជាក់ពីទិន្នន័យ មានបង្ហាញក្នុងតារាងខាងក្រោម ។

**តារាង ៤.៥:** លទ្ធផលនៃការពិនិត្យទិន្នន័យសំរាប់ការបង្កើតម៉ូដែលធុង

| WL-ស្ថានីយ | W-រយះពេលៈ | ស្ថានីយ៍ទឹកភ្លៀង | រយះពេលទឹកភ្លៀង | គណនា-រយះពេល |
|---|---|---|---|---|
| WT_3 | សីហា ០៣-មេសា ០៨ | ពួក | មិនា ០៣-ធ្នូ ០៨ | មករា ០៩-មេសា ០៨ |
| WT_4 | មិនា ០៧-មិនា ០៨ | ពួក | | មិនា ០៧-មិនា ០៨ |
| WT_5 | មិនា ០៧-មិនា ០៩ | ក្នុងក្រុង | មករា ៨៨-ធ្នូ ០៨ | ឧសភា ០៧-ធ្នូ ០៨ |
| WT_6 | កក្កដា ០៨-មិថុនា ០៩ | អង្គរធំ | កក្កដា ០០-ធ្នូ ០៨ | កក្កដា ០៨-ធ្នូ ០៨ |
| WT_7 | សីហា ០៣-មិថុនា ០៩ | អង្គរធំ ប្រាសាទបាគង | | កញ្ញា ០៣-ធ្នូ ០៨ |
| WT_8 | - | ក្នុងក្រុង | មករា ៨៨-ធ្នូ ០៨ | - |
| LTa | - | ក្នុងក្រុង | | - |
| LTb | កញ្ញា ០៣-មិថិនា ០៨ | ក្នុងក្រុង | | កញ្ញា ០៣-ធ្នូ ០៨ |

**WL-ស្ថានីយ៍:** លេខកូដអណ្តូងត្រួតពិនិត្យកំពស់ទឹកក្រោមដី។

**W-រយះពេល:** រយៈពេលនៃទិន្នន័យត្រួតពិនិត្យកំពស់ទឹកក្រោមដី ដែលអាចទុកចិត្តបាន សម្រាប់អណ្តូងនីមួយៗ ដែល ពិនិត្យដោយលទ្ធផលនៃការពិនិត្យដោយដៃ។

**ស្ថានីយ៍ទឹកភ្លៀង :** ឈ្មោះស្ថានីយ៍សង្កេតទឹកភ្លៀង។

**រយះពេលទឹកភ្លៀង:** រយៈពេលនៃការសង្កេតសម្រាប់ស្ថានីយ៍ឧតុនិយមនីមួយៗ។

**គណនា-រយះពេល :** រយៈពេលដែលទិន្នន័យនៃការពិនិត្យទឹកក្រោមដី និងការសង្កេតឧតុនិយម គឺមានសម្រាប់ការវិភាគ ម៉ូដែលធុង។

### ៤.៥.២. លទ្ធផលនៃការគណនាការបំពេញទឹកក្រោមដីមកវិញចំពោះទីតាំងត្រួតពិនិត្យនីមួយៗ

រូបភាព ៤.២៩ ដល់៤.៣៤ បង្ហាញពីលទ្ធផលនៃការវិភាគកំពស់ទឹកក្រោមដីដោយម៉ូដែលធុង នៅគ្រប់ទីតាំង អណ្តូងត្រួតពិនិត្យដែលមានដូចបង្ហាញក្នុងតារាង ៤.៥។




**រូបភាព ៤.២៩:** លទ្ធផលនៃការវិភាគកំពស់ទឹកក្រោមដីដោយម៉ូដែលធុង (WT-3)




**រូបភាព ៤.៣០:** លទ្ធផលនៃការវិភាគកំពស់ទឹកក្រោមដីដោយម៉ូដែលធុង (WT-4)




**រូបភាព ៤.៣១:** លទ្ធផលនៃការវិភាគកំពស់ទឹកក្រោមដីដោយម៉ូដែលធុង (WT-5)




**រូបភាព ៤.៣២:** លទ្ធផលនៃការវិភាគកំពស់ទឹកក្រោមដីដោយម៉ូដែលធុង (WT-6)




**រូបភាព ៤.៣៣:** លទ្ធផលនៃការវិភាគកំពស់ទឹកក្រោមដីដោយម៉ូដែលធុង (WT-7)




**រូបភាព ៤.៣៤:** លទ្ធផលនៃការវិភាគកំពស់ទឹកក្រោមដីដោយម៉ូដែលធុង (LTb)

### ៤.៥.៣. សង្ខេបការគណនាការបំពេញទឹកក្រោមដីមកវិញ

លទ្ធផលនៃការគណនា ការបំពេញទឹកក្រោមដីមកវិញ មានសង្ខេបក្នុងតារាងទាំងពីរខាងក្រោម ។

**តារាង ៤.៦:** ការបំពេញទឹកក្រោមដីមកវិញប្រចាំខែ និងឆ្នាំ ចំពោះស្ថានីយ៍និមួយៗ

| Month | WT3 | WT4 | WT5 | WT6 | WT7(1) | WT7(2) | LT_b |
|---|---|---|---|---|---|---|---|
| **Jan** | 0.0 | 0.0 | 1.0 | --- | 0.0 | 0.0 | 0.3 |
| **Feb** | 0.0 | 0.0 | 2.1 | --- | 0.0 | 0.0 | 4.3 |
| **Mar** | 6.4 | 13.9 | 2.5 | --- | 1.0 | 6.5 | 8.5 |
| **Apr** | 20.0 | 12.1 | 7.1 | --- | 4.0 | 6.4 | 13.6 |
| **May** | 74.4 | 82.4 | 17.1 | --- | 28.0 | 31.8 | 56.8 |
| **Jun** | 70.8 | 54.2 | 18.5 | 38.2 | 38.0 | 39.8 | 60.7 |
| **Jul** | 71.1 | 57.8 | 13.6 | 55.0 | 24.0 | 51.0 | 56.6 |
| **Aug** | 59.7 | 56.3 | 13.8 | 120.1 | 55.0 | 35.1 | 40.6 |
| **Sep** | 93.6 | 36.6 | 31.4 | 115.8 | 55.0 | 60.5 | 86.8 |
| **Oct** | 59.2 | 33.8 | 25.8 | 91.8 | 47.0 | 37.0 | 61.1 |
| **Nov** | 12.4 | 20.1 | 6.1 | 33.0 | 6.0 | 9.8 | 10.7 |
| **Dec** | 5.4 | 0.0 | 0.0 | 0.0 | 10.0 | 2.2 | 2.4 |
| **Yearly** | **473** | **367** | **139** | **>454** | **268** | **280** | **402** |

**តារាង៤.៧:** ការសង្ខេបនូវលទ្ធផលនៃការគណនារបស់ម៉ូដែលធុង

| Month | Precipitation | | | Groundwater Recharge | | | Evapotranspiration | | |
|---|---|---|---|---|---|---|---|---|---|
| | Max. | Avrag | Min. | Max. | Avrag | Min. | Max. | Avrag | Min. |
| Jan | 10.0 | 6.0 | 1.4 | 1.4 | 0.1 | 0.0 | 38.9 | 29.3 | 20.2 |
| Feb | 46.7 | 11.2 | 0.0 | 17.1 | 1.1 | 0.0 | 39.8 | 30.0 | 21.0 |
| Mar | 121.9 | 29.5 | 0.2 | 28.7 | 5.8 | 0.0 | 51.6 | 38.8 | 26.3 |
| Apr | 124.0 | 53.5 | 2.7 | 29.6 | 10.4 | 0.0 | 53.4 | 39.3 | 27.4 |
| May | 372.0 | 232.4 | 42.0 | 113.1 | 45.4 | 0.0 | 54.3 | 37.4 | 22.2 |
| Jun | 397.7 | 217.5 | 102.4 | 93.9 | 48.5 | 17.8 | 49.1 | 31.8 | 20.0 |
| Jul | 340.0 | 199.3 | 117.9 | 82.3 | 47.0 | 11.3 | 66.7 | 31.0 | 17.2 |
| Aug | 306.8 | 206.1 | 43.0 | 120.1 | 47.7 | 11.2 | 68.0 | 32.0 | 19.2 |
| Sep | 502.9 | 254.1 | 130.0 | 134.8 | 70.4 | 26.0 | 54.2 | 24.7 | 15.6 |
| Oct | 375.7 | 196.6 | 103.0 | 119.1 | 49.7 | 14.8 | 58.9 | 29.2 | 19.2 |
| Nov | 98.2 | 50.8 | 3.9 | 33.0 | 10.7 | 0.0 | 58.5 | 28.0 | 18.6 |
| Dec | 71.1 | 31.2 | 0.2 | 23.4 | 4.2 | 0.0 | 60.3 | 28.6 | 18.2 |

ការបំពេញមកវិញនូវទឹកក្រោមដី ជាមធ្យមប្រចាំឆ្នាំ គឺ៣៤១មីលីម៉ែត្រ ក្នុង១ឆ្នាំ ។ ការបំពេញមកវិញនូវទឹកក្រោមដី ប្រចាំឆ្នាំ នៅក្នុងតំបន់ដែលបំពេញមកវិញទាំងមូល គឺអាងស្ទឹងទាំងបី (សូមមើលតំបន់ដែលមានពណ៌លឿង ក្នុងរូបភាព៤.២) គឺ ៤៣៥៥១៧០០០ម៉ែត្រគីប ដែលស្មើបរិមាណប្រចាំថ្ងៃ ១១៩៣០០០ម៉ែត្រគីប ។

ម្យ៉ាងវិញទៀត ពុំមានស្រទាប់ដែលមានទឹកជ្រៅ ដែលមានលក្ខណៈជ្រាបទឹកខ្ពស់នោះទេ នៅក្នុងក្រុងសៀមរាប ដូចនេះ បរិមាណបំពេញមកវិញនូវទឹកក្រោមដី ក្នុងតំបន់សេវាកម្មផ្គត់ផ្គង់ទឹក ត្រូវគណនាដោយគុណ ៣៤១ មីលីម៉ែត្រ នឹង ៥៥២ គីឡូម៉ែត្រការេ ដើម្បីទទួលបានបរិមាណមធ្យមប្រចាំឆ្នាំចំនួន ១៨៨៣២០០០០ ម៉ែត្រគីប ដែលស្មើនឹង ៥១៦០០០ ម៉ែត្រគីប ក្នុងមួយថ្ងៃ ។

បើយើងប្រៀបធៀបតែបរិមាណនៃការបំពេញមកវិញពីទឹកភ្លៀង (៥១៦០០០ ម៉ែត្រគីប ក្នុងមួយថ្ងៃ) ទៅនឹងបរិមាណដែលមាន នៅក្នុងផែនការអភិវឌ្ឍន៍ការផ្គត់ផ្គង់ទឹក (៨៦.២៥០ ម៉ែត្រគីប ក្នុងមួយថ្ងៃ) យើងឃើញថា វាធំជាង៦ដង ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលយើងគិតដល់វដ្តជលសាស្ត្រនោះ កំពស់ទឹកក្រោមដី អាចចាត់ទុកថា មិនមានការប្រែប្រួលអ្វីទេ បើទោះជាមានបរិមាណទឹកភ្លៀងច្រើនដែលបំពេញទឹកក្រោមដីមកវិញក៏ដោយ ។ គឺមានន័យថា ក្រោមលក្ខខ័ណ្ឌធម្មជាតិ បរិមាណនៃការបំពេញទឹកក្រោមដីមកវិញត្រូវបានប្រើប្រាស់ ហើយការប្រើប្រាស់ទឹកក្រោមដីសំខាន់នោះ គឺវាមកពីការហួត ។

ការហួតទឹកក្រោមដី គឺវាពាក់ព័ន្ធនឹងកត្តាជាច្រើន ដូចជាការហួតពីផ្ទៃដី ជម្រៅកំពស់ទឹកក្រោមដី ប្រភេទដី ឬស្រទាប់ដែលមានទឹក និងកត្តាផ្សេងៗទៀត ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ការវិភាគទូទៅ តម្លៃជម្រៅ៥ម៉ែត្រ អាចត្រូវយកមកគិត ជាជម្រៅមួយដែលមានការហួតទឹកក្រោមដី ។ ដូចនេះ កំពស់ទឹក

ក្រោមដីនឹងមានក្នុងជម្រៅ៥ម៉ែត្រ ក្រោមផ្ទៃដី ក្នុងតំបន់ក្រុងសៀមរាបទាំងមូល ក្នុងករណីដែលបរិមាណនៃការបូមយកទឹកក្រោមដីស្មើ នឹងបរិមាណនៃការបំពេញមកវិញ ។

## ៤.៦-ការពិនិត្យទឹកក្រោមដីក្នុងពេលស្របគ្នា

### ៤.៦.១-របាយ និងការផ្លាស់ប្តូរកំពស់ទឹកក្រោមដី

ដើម្បីបញ្ជាក់ច្បាស់ ពីរបាយកំពស់ទឹកក្រោមដី ក្នុងក្រុងសៀមរាប ការពិនិត្យលើទឹកក្រោមដីស្របពេលគ្នា ត្រូវបានធ្វើឡើងពីរដង ក្នុងរដូវវស្សាក្នុងខែកញ្ញា ឆ្នាំ២០០៩ និងរដូវប្រាំង ក្នុងខែមេសា ឆ្នាំ២០១០។ របាយកំពស់ទឹកក្រោមដីនេះ ក៏បានបង្ហាញឃើញដូចគ្នាផងដែរ តាមរយៈការអង្កេតកំពស់ទឹកក្រោមដី ទាំងពីរលើក ។ រូបភាព៤.៣៥ បង្ហាញពីលទ្ធផលនៃការវិភាគទឹកក្រោមដី ក្នុងរដូវវស្សា ។ រូបភាព៤.៣៦ បង្ហាញពីភាពខុសគ្នានៃកំពស់ទឹកក្រោមដី រវាងរដូវទាំងពីរ។

ការស្រកចុះដ៏ខ្លាំងនៃទឹកក្រោមដីក្នុងរដូវប្រាំង អាចឃើញមានក្នុងរូបភាព ៤.៣៦ ។ អណ្តូងឯកជនជាច្រើនជាអ្នកប្រើទឹកក្រោមដីធំៗ ដូចជា សណ្ឋាគារ និងផ្ទះសំណាក់ គឺប្រើទឹកក្រោមដីក្នុងតំបន់ទីក្រុង ។ នេះគឺជាមូលហេតុនៃការស្រកចុះកំពស់ទឹកក្រោមដីដ៏ខ្លាំងក្នុងតំបន់ទីក្រុង ច្រើនជាងតំបន់ឯទៀតក្នុងខេត្តសៀមរាប ។

### ៤.៦.២-ការសង្កេតលើកំពស់ទឹកក្រោមដីក្នុងការសិក្សាលើកមុនរបស់ JICA

ក្នុងការសិក្សាស្តីពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសំរាប់តំបន់សៀមរាប ក្នុងប្រទេសកម្ពុជា (ឆ្នាំ២000) អណ្តូងចំនួន៧៩ ត្រូវបានប្រើសំរាប់ការសង្កេតកំពស់ទឹកក្រោមដីប្រចាំខែ ពីខែកុម្ភៈ ឆ្នាំ១៩៩៨ រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៩៩ ។




**រូបភាព ៤.៣៥:** លទ្ធផលនៃការសង្កេត ទឹកក្រោមដី ស្របពេលគ្នា ក្នុងរដូវវស្សា (ខែកញ្ញា ឆ្នាំ២០០៩)




**រូបភាព ៤.៣៦៖** ការប្រែប្រួលកំពស់ ទឹកក្រោមដី ចន្លោះរវាង រដូវវស្សា (ខែកញ្ញា ឆ្នាំ២០០៩) និង រដូវប្រាំង (ខែមេសា ឆ្នាំ២០១០)

## ៤.៧-ការប្រៀបធៀបលទ្ធផលនៃការពិនិត្យទឹកក្រោមដី

នៅក្នុងការសិក្សារបស់ JICA ទាំងពីរ ការសិក្សាលើកនេះ និងការសិក្សាស្តីពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសំរាប់តំបន់សៀមរាប ក្នុងប្រទេសកម្ពុជា (ឆ្នាំ២០០០) អណ្តូងភាគច្រើន ដែលមាននៅតាមបណ្តោយផ្លូវជាតិលេខ៦ និងផ្លូវពីប្រាសាទអង្គរវត្តទៅបឹងទន្លេសាប ត្រូវបានជ្រើសរើស សម្រាប់ការពិនិត្យលើ កំពស់ទឹកក្រោមដី ។ គ្រប់អណ្តូងទាំងអស់ ក្នុងចម្ងាយ១គីឡូម៉ែត្រ ពីផ្លូវធំៗពីរ ក្នុងក្រុងសៀមរាប ត្រូវបានបូម សម្រាប់ប្រៀបធៀបលើការប្រែប្រួលកំពស់ទឹក ។

### ៤.៧.១-រដូវដែលមានកំពស់ទឹកក្រោមដីខ្ពស់

កំពស់ទឹកក្នុងរដូវវស្សា ក្នុងការសិក្សារបស់ JICAទាំងពីរ មានសង្ខេបនៅក្នុងតារាង និងរូបភាពខាងក្រោម ។ កំពស់ទឹកក្នុងឆ្នាំ២០០៩ មានទាបជាងឆ្នាំ១៩៩៩ ប៉ុន្តែស្ទើរតែដូចគ្នានឹងឆ្នាំ១៩៩៨ ។

**តារាង ៤.៨:** ការប្រៀបធៀបកំពស់ទឹកក្នុងរដូវវស្សា ដោយអណ្តូងតាមបណ្តោយផ្លូវធំៗ

| ពេល | កញ្ញា០៩ | កញ្ញា៩៨ | តុលា ៩៨ | វិច្ឆិកា៩៨ | កញ្ញា ៩៩ | តុលា ៩៩ | វិច្ឆិកា៩៩ |
|---|---|---|---|---|---|---|---|
| មធ្យម (m) | 1.58 | 1.57 | 1.32 | 1.39 | 1.2 | 0.84 | 0.61 |
| អតិបរមា (m) | 5.12 | 6.83 | 5.88 | 5.79 | 5.21 | 4.21 | 3.13 |
| អប្បបរមា (m) | 0.2 | 0.1 | 0 | 0.08 | -0.06 | -0.44 | -0.49 |

**សំគាល់:** តម្លៃលេខក្នុងតារាង គឺជា តម្លៃកំពស់ទឹកនៅក្រោមផ្ទៃដី ។




**រូបភាព ៤.៣៧:** ការប្រៀបធៀបរវាងកំពស់ទឹកមធ្យមក្នុងរដូវវស្សា ដោយអណ្តូងនៅតាមបណ្តោយផ្លូវធំៗ

### ៤.៧.២-រដូវដែលមានកំពស់ទឹកក្រោមដីទាប

កំពស់ទឹកក្នុងរដូវប្រាំង ក្នុងការអង្កេតនេះ (ខែមេសា ឆ្នាំ២០០៩) គឺមានទាប ជាងកំពស់ទឹក នៅក្នុងគ្រប់ខែដូចគ្នា ក្នុងរដូវប្រាំង នាឆ្នាំ១៩៩៨ និង១៩៩៩ ។

**តារាង ៤.៩:** ការប្រៀបធៀបនូវកំពស់ទឹកក្នុងរដូវប្រាំង ដោយអណ្ដូងនៅតាមបណ្ដោយផ្លូវធំៗ

| **ពេល** | **មេសា ១០** | **មេសា ៩៨** | **មិថុនា ៩៨** | **មេសា ៩៩** | **មិថុនា ៩៩** |
|---|---|---|---|---|---|
| មធ្យម (m) | 3.97 | 3.48 | 3.48 | 2.7 | 2.28 |
| អតិបរមា (m) | 9.12 | 8.52 | 8.52 | 9.22 | 7.4 |
| អប្បបរមា (m) | 1.73 | 0.99 | 0.99 | 0.65 | -0.05 |

**សំគាល់:** តម្លៃលេខក្នុងតារាង គឺជា តម្លៃកំពស់ទឹកនៅក្រោមផ្ទៃដី ។




**រូបភាព ៤.៣៨:** ការប្រៀបធៀបរវាងកំពស់ទឹកមធ្យមក្នុងរដូវប្រាំង ដោយអណ្ដូងនៅតាមបណ្ដោយផ្លូវធំៗ

### ៤.៧.៣-ការប្រៀបធៀបលទ្ធផលក្នុងតំបន់ទីក្រុង

ដើម្បីពិនិត្យលើការប្រែប្រួលកំពស់ទឹក ក្នុងតំបន់ទីក្រុង គ្រប់អណ្ដូងទាំងអស់ ក្នុងការសិក្សាផ្សេងៗគ្នា នៅក្នុងតំបន់ទីក្រុង ត្រូវបានជ្រើសរើស ។ ក្នុងចំណោមអណ្ដូងចំនួន៣៣ ដែលបានជ្រើសរើស ដែលបានពិនិត្យក្នុងការសិក្សានេះ មាន២៣អណ្ដូង ត្រូវបានប្រើសម្រាប់វាស់កំពស់ទឹកក្រោមដី ក្នុងរដូវវស្សា និង២៩អណ្ដូង ក្នុងរដូវប្រាំង ។ ក្នុងចំណោមអណ្ដូងចំនួន២៨ ដែលបានជ្រើសរើសពីការសិក្សាលើកមុនរបស់ JICA មាន១៣អណ្ដូង ដែលមានទិន្នន័យសម្រាប់ការ

ប្រៀបធៀបនេះ ។ រាល់ទិន្នន័យដែលមានទាំងអស់ មានសង្ខេប ក្នុងរដូវផ្សេងៗគ្នា ហើយលទ្ធផលរបស់វា មានបង្ហាញក្នុងតារាង និងរូបភាពខាងក្រោម ។

**តារាង ៤.១០:** ការប្រៀបធៀបកំពស់ទឹកក្នុងរដូវវស្សា ក្នុងតំបន់ក្រុង

| **ពេល** | **កញ្ញា០៩** | **កញ្ញា៩៨** | **តុលា ៩៨** | **វិច្ឆិកា៩៨** | **កញ្ញា ៩៩** | **តុលា ៩៩** | **វិច្ឆិកា៩៩** |
|---|---|---|---|---|---|---|---|
| មធ្យម (m) | 1.63 | 1.41 | 1.2 | 1.32 | 1.24 | 0.85 | 0.6 |
| អតិបរមា (m) | 5.12 | 3.51 | 3.1 | 3 | 3.26 | 2.9 | 2.32 |
| អប្បបរមា (m) | 0.2 | 0.1 | 0 | 0.3 | 0.23 | -0.28 | -0.41 |

**សំគាល់:** តម្លៃលេខក្នុងតារាង គឺជា តម្លៃកំពស់ទឹកនៅក្រោមផ្ទៃដី ។




**រូបភាព ៤.៣៩:** ការប្រៀបធៀបរវាងកំពស់ទឹកមធ្យមក្នុងរដូវវស្សា ក្នុងតំបន់ក្រុង

តារាង៤.១០ បង្ហាញពីភាពខុសគ្នាយ៉ាងជាក់ស្តែង រវាងកំពស់ទឹកនៅក្នុងរដូវវស្សា ក្នុងការសិក្សានេះ ទៅនឹងការសិក្សាលើកមុន ។ បើប្រៀបធៀបទៅនឹងលទ្ធផលនៃការអង្កេតក្នុងឆ្នាំ១៩៩៨ និង១៩៩៩ កំពស់ទឹក ក្រោមដី ក្នុងឆ្នាំ២០០៩ មានការស្រកចុះក្នុងកម្រិតពី០.២២ម៉ែត្រ ទៅ១.០៣ម៉ែត្រ ។

**តារាង ៤.១១:** ការប្រៀបធៀបនូវកំពស់ទឹកក្នុងរដូវប្រាំង ក្នុងតំបន់ក្រុង

| ពេល | មេសា ១០ | មេសា ៩៨ | មិថុនា ៩៨ | មេសា ៩៩ | មិថុនា ៩៩ |
|---|---|---|---|---|---|
| មធ្យម (m) | 4.19 | 3.5 | 3.5 | 2.5 | 2 |
| អតិបរមា (m) | 7.4 | 5 | 5.1 | 4.6 | 4.81 |
| អបបរមា (m) | 2.6 | 2.35 | 2.25 | 1.46 | 0.82 |

**សំគាល់:** តម្លៃលេខក្នុងតារាង គឺជា តម្លៃកំពស់ទឹកនៅក្រោមផ្ទៃដី។




**រូបភាព ៤.៤០:** ការប្រៀបធៀបរវាងកំពស់ទឹកមធ្យមក្នុងរដូវប្រាំង ក្នុងតំបន់ក្រុង

តារាងទាំងពីរ ៤.១០ និង ៤.១១ បានបង្ហាញពីភាពខុសគ្នាយ៉ាងជាក់ស្តែងនៃកំពស់ទឹក រវាងខែកញ្ញា ឆ្នាំ២០០៩ (ខែមេសា ឆ្នាំ២០១០) និងខែដូចគ្នា នៅក្នុងឆ្នាំ១៩៩៨ និង១៩៩៩ ។ ទោះជាយ៉ាងណាក៏ដោយ ភាពខុសគ្នានេះ មានធំជាងនេះទៅទៀត បើសិនជា យើងប្រើតែអណ្តូងក្នុងតំបន់ទីក្រុង សម្រាប់ការប្រៀបធៀប ជាជាងប្រើអណ្តូងទាំងអស់នៅជិតផ្លូវធំៗ សម្រាប់ការប្រៀបធៀបនោះ ។ មានន័យថា ការស្រកចុះនៃកំពស់ទឹកក្រោមដី ក្នុងតំបន់ក្រុង គឺច្រើនជាងតំបន់ផ្សេងទៀត ក្នុងខេត្ត សៀមរាប ដោយសារតែអណ្តូងឯកជនជាច្រើន គឺស្ថិតនៅតំបន់ក្រុង ដែលមានចំនួនច្រើននោះ ។